# សេចក្ដីជូនដំណឹង

THE CHURCH OF JESUS CHRIST OF LATTER-DAY SAINTS

កាលបរិច្ឆេទ ៖ ថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ ២០២០

គោរពជូន ៖ ពួកអ្នកមានសិទ្ធិអំណាចទូទៅ ពួកអ្នកកាន់តំណែងទូទៅពួកចិតសិបនាក់ប្រចាំតំបន់ ប្រធានស្តេក ប្រធានបេសកកម្ម និង ប្រធានមណ្ឌល ប៊ីស្សព និង ប្រធានសាខាទាំងឡាយ

មកអំពី ៖ ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា

កម្មវត្ថុ ៖ ការផ្លាស់ប្តូរថ្នាក់សិក្ខាសាលាក្នុងឆ្នាំ២០២១—*ចូរមកតាមខ្ញុំ និង លក្ខខណ្ឌនានា*

---

ចាប់ផ្តើមពីថ្ងៃទី ០១ខែមករាឆ្នាំ ២០២១ការកែត្រូវខាងក្រោមនឹងធ្វើឡើង នៅក្នុងកម្មវិធីថ្នាក់សិក្ខាសាលា ៖

## ការផ្លាស់ប្តូរលក្ខខណ្ឌក្នុងការអាន

ដើម្បី ទទួលបានក្រេឌីតសម្រាប់ បញ្ចប់វគ្គសិក្សាសិស្សត្រូវអានព្រះគម្ពីរដែលត្រូវសិក្សាក្នុងឆ្នាំនេះយ៉ាងតិច ៧៥% នៃថ្ងៃក្នុងប្រតិទិនប្រចាំឆមាស ។ ការផ្លាស់ប្តូរនេះសង្កត់ធ្ងន់ទៅលើចំនុចសំខាន់សម្រាប់សិស្សដើម្បីអភិវឌ្ឍន៍ទម្លាប់នៃការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ដើម្បីជួយឲ្យមានការយល់ដឹងនិង ការទុកចិត្តលើព្រះយេស៊ូវ គ្រីស្ទការបង្រៀន និងដង្វាយធួនរបស់ទ្រង់កាន់តែខ្លាំង ។

គ្រូបង្រៀនគួរបន្តលើកទឹកចិត្តសិស្សឲ្យដាក់គោលដៅអានផ្ទាល់ខ្លួន និងអានអត្ថបទពីវគ្គសិក្សាប៉ុន្តែការណ៍ធ្វើដូចនេះលែងជាតម្រូវការសម្រាប់វគ្គសិក្សាជាក្រេឌីតទៀតហើយ ។

## បញ្ចូលកម្មវិធី *ចូរមកតាមខ្ញុំ* បន្ថែម

ជំនួសឲ្យទម្លាប់នៃការធ្វើតាមកម្មវិធីសិក្សា ថ្នាក់សិក្ខាសាលារយៈពេល៩ ខែនោះមេរៀននឹងដាក់បញ្ចូលជាមួយ សំណើឲ្យអានរយៈពេល១២ ខែតាមកាលវិភាគ*ចូរមកតាមខ្ញុំ*។ សម្រាប់ឆ្នាំសិក្សា២០២១គ្រូបង្រៀននឹងប្រើសៀវភៅសិក្សា *គោលលទ្ធិ និង សេចក្តីសញ្ញា និង ប្រវត្តិសាសនាចក្រ* ដែលមានស្រាប់ជាឯកសារមេរៀន ។ ការកែតម្រូវនេះមានន័យថាសិស្សនឹងមិនទទួលគ្រប់មេរៀនពីសៀវភៅ សិក្សាសម្រាប់គ្រូបង្រៀននៅក្នុងថ្នាក់ទេ ជាពិសេសគឺមេរៀនទាំងឡាយ ដែលមាននៅក្នុងប្រតិទិន *ចូរមកតាមខ្ញុំ* ពេលសាលាវិស្សមកាល ។

ឥឡូវនេះមាន ធនធានសម្រាប់បំពាក់បំប៉នដើម្បីគាំទ្រដល់អ្នកគ្រប់គ្រងកម្មវិធីនិងគ្រូបង្រៀនក្នុងការអនុវត្តន៍តាមការផ្លាស់ប្តូរដែលរួមមានទាំង *Quick-Start Guide to Daily Scripture Study Goals* (ChurchofJesusChrist.org/go/5VJ) ។